ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍
លេខ:០៤៥ កប/គបអ

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍
<u>សូមគោរពជូន</u>
ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

កម្មវត្ថុ: របាយការណ៍បូកសរុបលទ្ធផលការងារស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆមាសទី១ និងទិសដៅអនុវត្តឆមាសទី២ឆ្នាំ២០១៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍សូមជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** មេត្តាជ្រាបដូចខាងក្រោម:

ក- <u>លទ្ធផលការងារដែលសម្រេចបាន:</u>

I-<u>ការប្រជុំ និងការងារផ្សេងៗរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង</u>

-សិក្ខាសាលាផ្សព្វផ្សាយកម្មវិធីផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរហ័សរកមេរោគអេដស៍ដោយការជោះឈាមពីចុងម្រាមដៃក្រោមអធិបតីភាព ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានសិក្ខាកាមចូលរួមចំនួន ២៧ នាក់ (ស្ត្រី ១០នាក់) រៀបចំដោយលេខាធិការដ្ឋានអេដស៍សហការជាមួយសម្ព័ន្ធពាណិជ្ជកម្មកម្ពុជាប្រយុទ្ធនឹងជំងឺអេដស៍ (CBCA) នៅថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០១៣ នៅសាលប្រជុំនាយកដ្ឋានពេទ្យការងារ។

-ប្រជុំប្រចាំត្រីមាស ចំនួន ០២ លើក របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រោមអធិបតីភាពឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានសមាជិកចូលរួមចំនួន ៤៩ នាក់ (ស្ត្រី ១០នាក់) នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ និងថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០១៤ នៅទីស្តីការក្រសួង។

-កិច្ចប្រជុំបូកសរុបលទ្ធផលការងារគម្រោងសុខភាពនៅកន្លែងធ្វើការប្រចាំឆ្នាំ ២០១៣ និងទិសដៅឆ្នាំ ២០១៤ ក្រោមអធិបតីភាព ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរៀបចំដោយលេខាធិការដ្ឋានអេដស៍សហការជាមួយអង្គការរ៉ាក់ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤នៅទីស្តីការក្រសួង។

-កិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ស្តីពីសុខភាពមាតា និងទារក នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០១៤ នៅលេខាធិការដ្ឋានអេដស៍ជាមួយអង្គការយែរកមជា។

-កិច្ចប្រជុំពិភាក្សារៀបចំខ្លឹមសារ និងបែងចែកប្រធានបទបំណិនជីវិត នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ នៅលេខាធិការដ្ឋានអេដស៍ជាមួយអង្គការ CRS។

-កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងកម្មវិធីសិក្សាបំណិនជីវិតស្តីពីការអប់រំសុខភាពនៅកន្លែងសិក្សា នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ សហការជាមួយអង្គការ CRS។

-សិក្ខាសាលាបំណិនជីវិតស្តីពីការអប់រំសុខភាពនៅកន្លែងសិក្សា ដែលមានសិក្ខាកាមចូលរួមចំនួន១៥នាក់ (ស្រី៥នាក់)នៅថ្ងៃទី០៩-១០ ខែមេសា ឆ្នាំ២០១៤ នៅទីស្តីការក្រសួងសហការជាមួយអង្គការ CRS។

-បើកវគ្គបណ្តុះបណ្តាលកម្មវិធីសិក្សាបំណិនជីវិត ស្តីពីការអប់រំសុខភាពនៅកន្លែងសិក្សាដល់មន្ត្រីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រីនៅតាមវិទ្យាស្ថាន ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាព ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ០៣ខេត្ត(ខេត្តតាកែវ ខេត្តកំពត និងខេត្តស្វាយរៀង)សរុបសិក្ខាកាមចូលរួម ៤៦នាក់(ស្រី១១នាក់)។

-ចុះតាមដាន និងវាយតម្លៃលើដំណើរការបង្រៀនបំណិនជីវិត ស្តីពីការអប់រំសុខភាពនៅកន្លែងសិក្សានៅវិទ្យាស្ថានពហុបច្ចេកទេសតេជោសែនខេត្តតាកែវ និងខេត្តកំពត។

II-<u>ការងារអប់រំអេដស៍ដល់ពលករត្រៀមទៅធ្វើការនៅប្រទេសកូរ៉ែ(៥មេរៀន)</u>

-បានផ្តល់ចំណេះដឹងពីស្ថានភាព មូលដ្ឋានគ្រឹះមេរោគអេដស៍ និងជំងឺអេដស៍ ជំងឺកាមរោគ គ្រឿងញៀន ការប្រើស្រោមអនាម័យដល់ពលករត្រៀមចាកចេញទៅធ្វើការនៅប្រទេសកូរ៉េរៀបចំនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) ចំនួន ១១ វគ្គ សរុប ១.៧៤១ នាក់ ក្នុងនោះស្ត្រីចំនួន ៥៥៤ នាក់ និងបុរស ១.១៨៧ នាក់ (ឧស្សាហកម្ម ៥៨៣ នាក់ កសិកម្ម ៩៩៦ នាក់ និងសំណង់ ១៦២ នាក់)(ជូនភ្ជាប់នូវតារាងឧបសម្ព័ន្ធ)។

III-<u>ការងារចូលរួមប្រជុំ និងសិក្ខាសាលាជាមួយស្ថាប័នពាក់ព័ន្ធ</u>

-ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិ ចូលរួមដោយ ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

-ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការបង្កើតយន្តការឆ្ពោះទៅរកគោលនយោបាយជាតិគ្រប់គ្រងគ្រឿងស្រវឹងនៅកម្ពុជាចូលរួមដោយ ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង នៅថ្ងៃទី២៧

ខែមករា ឆ្នាំ២០១៤ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

-មន្ត្រីលេខាធិការដ្ឋានអេដស៍៤រូបចូលរួមសិក្ខាសាលារំលឹកដល់គ្រូបង្គោលរបស់គម្រោងស្តីពី "កន្លែងធ្វើការមានសុវត្ថិភាព និងសហគមន៍មានសុវត្ថិភាព" រៀបចំដោយអង្គការយែរកម្ពុជា នៅថ្ងៃទី២៧ ដល់២៨ ខែកុម្ភៈ ឆ្នាំ២០១៤ នៅភោជនីយដ្ឋានខ្មែរសុរិន្ទ។

-ចូលរួមកិច្ចប្រជុំលើកទី១ក្រុមការងារបច្ចេកទេសថ្នាក់ជាតិស្តីពីយុទ្ធសាស្ត្រទី៦ ចូលរួមដោយ លោកស្រី ឃុន សុខស៊ីណាក់ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

-ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការផ្សៀងផ្ងាត់លើរបាយការណ៍វឌ្ឍនភាពជាសកលឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា រៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចូលរួមដោយលោក ជួរ អៀងលី នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា។

-ចូលរួមកិច្ចប្រជុំលើកកំពស់សកម្មភាពអប់រំនៅក្នុងរោងចក្រ(SAFE Meeting)ចូលរួមដោយលោក អ៊ុំ វីរៈ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ រៀបចំដោយអង្គការយែរកម្ពុជា នៅសណ្ឋាគារឡាជាវ៉ាន់ដា។

-ចូលរួមកិច្ចប្រជុំសម្របសម្រួលថ្នាក់ជាតិស្តីពីការអនុវត្តបទអន្តរាគមន៍បង្ការមេរោគអេដស៍និងជំងឺអេដស៍ក្នុងចំណោមបុរសស្រលាញ់បុរស និងស្រីស្រស់ ចូលរួមដោយលោកស្រី មៅ ធីតា នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នៅសណ្ឋាគារភ្នំពេញ។

-មន្ត្រីលេខាធិការដ្ឋានអេដស៍៤រូបចូលរួមសិក្ខាសាលាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ឆ្ពោះទៅសម្រេចបាននូវគោលដៅសូន្យបីសម្រាប់ថ្នាក់ជាតិ រៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី០៣-០៦ ខែមិថុនា ឆ្នាំ២០១៤ នៅសណ្ឋាគារសោមាទេវីខេត្តសៀមរាប។

-ចូលរួមប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចូលរួមដោយ ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ នៅអគារមិត្តភាពទីស្តីការគណៈរដ្ឋមន្ត្រី។

ខ-<u>ទិសដៅអនុវត្តបន្ត</u>

-បើកវគ្គបណ្តុះបណ្តាលកម្មវិធីសិក្សាបំណិនជីវិតស្តីពីការអប់រំសុខភាពនៅកន្លែងសិក្សាដល់មន្ត្រីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ០៤។

-បន្តអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍ដល់សិស្ស និស្សិត និងពលករទៅធ្វើការនៅសាធារណរដ្ឋកូរ៉េនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC)។

-បន្តការបណ្តុះបណ្តាលស្តីពីលក្ខខណ្ឌការងារល្អប្រសើរក្នុងវិស័យកាត់ដេរដល់ក្រុមជួយក្រុម ប្រតិភូបុគ្គលិក និងកម្មករនិយោជិតទូទៅ។

-បន្តកិច្ចសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (NAA) អង្គការ CRS អង្គការ ILO និងអង្គការ CARE ។

-ចូលរួមប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលជាមួយស្ថាប័នពាក់ព័ន្ធ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម**ឯកឧត្តម**មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

រាជធានីភ្នំពេញថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៩

ប្រធាន

ខៀវ. ហ៊ុយ ហានសុខ

ចម្លងជូន:
-នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ
នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
-ឯកសារ-កាលប្បវត្តិ

10-7-14.

តារាងប្រៀបធៀប ៖ ការអប់រំមេរោគអេដស៍/ជំងឺអេដស៍

ល.រ	បរិយាយ	កេទ	ធមាសទី១ឆ្នាំ ២០១៤	ធមាសទី១ឆ្នាំ ២០១៣	ប្រៀបធៀប (%)
			១	២	៣=(១-២)/២
១	ការអប់រំមេរោគអេដស៍/ជំងឺអេដស៍ ដល់ពលករត្រៀមទៅធ្វើការនៅប្រទេសកូរ៉	សរុប	១.៧៤១	២.៤៨៣	-២៩.៨៨
		ស្រី	៥៥៤	៦៨៩	-១៩.៥៩

ប្រភព៖ លេខាធិការដ្ឋានអេដស៍ប្រចាំធមាសទី១ឆ្នាំ២០១៤